ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម

# ដំណាំសាវម៉ាវ



ផលិតដោយៈ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឆ្នាំ២០១៦

# សៀវភៅ

# ស្តីពី

# ដំណាំសាវម៉ាវ

រៀបចំដោយ

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម

បោះពុម្ពលើកទី១ ចំនួន ២០០០ ច្បាប់

ម.ព.ឯ.ក AIDOC
Code:
Date:
Donated by:

ផលិតដោយៈ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម
ឧបត្ថម្ភការបោះពុម្ពផ្សាយដោយៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

រក្សាសិទ្ធដោយៈ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

# សមាសភាពចូលរួមចំណែកផលិតសៀវភៅ
# ស្តីពីដំណាំសាវម៉ាវ

I. ទីប្រឹក្សាផ្តល់យោបល់:

១. បណ្ឌិត **ម៉ាក់ សឿន** អគ្គនាយកដ្ឋានកសិកម្ម

២. បណ្ឌិត **ម៉ៅ មីនា** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

៣. លោក **ប៉ែន វុទ្ធី** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

៣. លោក **គឹម ដារ៉ា** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

II. អ្នករៀបរៀង:

១. លោក **ផាន ទូច** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

III. ក្រុមអ្នកស្រាវជ្រាវ:

១. លោក **ហេង វុទ្ធី** សាកលវិទ្យាល័យភូមិន្ទកសិកម្ម

IV. ក្រុមការងារត្រួតពិនិត្យ និងកែសម្រួល:

១. លោក **កេត សំអាត** នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ

២. លោក **ពេជ សុវត្ថារ៉ា** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

៣. លោក **ហុង ទ្រី** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

៤. លោក **ផន ប្រុស** នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ





## មាតិកា　　　　　　　　　　　　　　　　　　　　ទំព័រ


**១. សេចក្តីផ្តើម** .................................................... ០១

**២. ស្ថានភាពទូទៅនៃដំណាំសាវម៉ាវ** .................................... ០១

២.១ ស្ថានភាពដំណាំសាវម៉ាវនៅកម្ពុជា ................................ ០២

**៣. លក្ខណៈរូបសាស្ត្រនៃដំណាំសាវម៉ាវ** ................................ ០២

៣.១ លក្ខណៈដើម ........................................................ ០២

៣.២ លក្ខណៈឫស ........................................................ ០៣

៣.៣ លក្ខណៈស្លឹក ....................................................... ០៣

៣.៤ លក្ខណៈផ្កា ........................................................ ០៤

៣.៥ លក្ខណៈផ្លែ ........................................................ ០៥

៣.៦ លក្ខណៈសំបក គ្រាប់ ............................................. ០៥

**៤. លក្ខណៈបរិស្ថាន អាកាសធាតុ ដី សម្រាប់ ដំណាំសាវម៉ាវ** .............................................. ០៦

៤.១ សំណើមបរិយាកាស ............................................... ០៦

៤.២ ទឹកភ្លៀង ............................................................ ០៦

៤.៣ សំណើម ............................................................ ០៦

៤.៤ សីតុណ្ហភាព ........................................................ ០៦

៤.៥ ពន្លឺ ................................................................ ០៧

៤.៦ ដី .................................................................. ០៧

**៥. អំពីពូជ** ............................................................ ០៧

៥.១ ការជ្រើសរើសពូជ ................................................. ០៨

៥.២ ការបន្តពូជរបស់ដំណាំសាវម៉ាវ..........០៩
**៦. បច្ចេកទេសដាំដុះ**..........១២
៦.១ ការជ្រើសរើសចម្ការ..........១២
៦.២ វិធីសាស្ត្រដាំកូនសាវម៉ាវ..........១៥
**៧. ការថែទាំ**..........១៧
៧.១ ការកាត់តែងមែក..........១៧
៧.២ ការស្រោចស្រព..........១៨
៧.៣ ការប្រើប្រាស់ជី..........១៩
**៨. កត្តាចង្រៃលើដំណាំសាវម៉ាវ**..........២១
៨.១ សត្វល្អិតចង្រៃ..........២១
៨.២ ជំងឺលើដំណាំសាវម៉ាវ..........២៣
៨.៣ ពពួករុក្ខជាតិចង្រៃ..........២៨
**៩. ការប្រមូលផល**..........២៨
៩.១ វិធីសាស្ត្រប្រមូលផល..........៣០



# ដំណាំសាវម៉ាវ

## ១. សេចក្តីផ្តើម

ដំណាំសាវម៉ាវជាប្រភេទឈើហូបផ្លែ ស្ថិតក្នុងអំបូរ Sapindaceac ថ្នាក់ឌីកូទីលេដូនដែលមានឈ្មោះវិទ្យាសាស្ត្រ Nephelium Lappaecum និងឈ្មោះជាភាសារអង់គ្លេស Rambutan ។

ផ្លែសាវម៉ាវមានរសជាតិផ្អែម និងជូរបន្តិចនៅពេលណាយើងបេះវាមកទុកក្នុងរយៈពេលខ្លី ។ ក្រៅពីតម្រូវការហូបផ្លែស្រស់ គេអាចយកទៅកែច្នៃដាក់ក្នុងកំប៉ុងធ្វើជាសាវម៉ាវកំប៉ុង ប៉ុន្តែ រសជាតិរបស់វាត្រូវបានថយចុះបន្តិច ។

ផ្នែកឱសថ ផ្លែរបស់សាវម៉ាវ គេអាចយកទៅធ្វើជាថ្នាំសម្រាប់ឃាត់ឈាម ឬសធ្វើជាថ្នាំព្យាបាលជំងឺគ្រុនក្តៅ ដោយយកឫសនេះទៅរំងាស់នឹងទឹក ។

រីឯសំបករបស់វា គេយកទៅធ្វើជាថ្នាំសម្រាប់ព្យាបាលជំងឺឈឺក្បាល ដោយយកសំបកទៅរោលនឹងរងើកភ្លើង ហើយយកក្រណាត់រុំ រួចយកមកស្អំក្បាល ។

នៅក្នុងផ្លែសាវម៉ាវមួយផ្លែ ទម្ងន់របស់វាអាចពី១៨ រហូតដល់៤៥ ក្រាម ហើយបើយើងបរិភោគមានបរិមាណសារធាតុទឹកចំនួន ៨២៩ ក្រាម ប្រូតេអ៊ីន ៩ ក្រាម ខ្លាញ់ 0.១ ក្រាម កាបូនអ៊ីដ្រាត ១៤៥ ក្រាម ជាតិសរសៃ ១១ ក្រាម វីតាមីន A និងវីតាមីន C ៣១ មីលីក្រាម កម្លាំងថាមពលគឺ ២៦៤ Kj /១00ក្រាម ។ បញ្ចូលគ្រាប់ផ្តល់នូវសារធាតុជ័ររឹងពី ៣0 - ៣៤% ហើយផ្ទុកសារធាតុអាស៊ីត Arachidic ខ្ពស់ ៣៤៧% និងអាស៊ីត Oleic (42.5%) បន្ទាប់ពីយើងយកវាទៅដុតកំដៅ ជ័ររបស់វាបានប្រែពណ៌ទៅជាពណ៌លឿង និងមានក្លិនក្រអូប ។

## ២. ស្ថានភាពទូទៅនៃដំណាំសាវម៉ាវ

ដំណាំសាវម៉ាវគ្មានប្រភពកំណើតច្បាស់លាស់ទេ ប៉ុន្តែគេឃើញរបាយរបស់វាដុះនៅភាគខាងត្បូងនៃប្រទេស ចិន "នៅយូណាន និង ហៃណាន" រហូតមកដល់

តំបន់ឥណ្ឌូចិន ម៉ាឡេស៊ី ឥណ្ឌូនេស៊ី នៅ Sumatra, Java, Kaimantan, Sulawesi និងនៅប្រទេស Philipiness។

ដំណាំសាវម៉ាវ ត្រូវបានគេដាំនៅពាសពេញតំបន់ត្រូពិចសើម នៃទ្វីបអាស៊ី ដូចជា Srilankato Newsguina ហើយមួយចំនួនតូចទៀតនៅក្នុងតំបន់ត្រូពិចសើម នៃប្រទេសអាមេរិក អាហ្វ្រិក និង អូស្ត្រាលី ( Prosea. Plant Resouces of South East Asia )។

## ២.១ ស្ថានភាពដំណាំជំឡូងមីនៅកម្ពុជា

នៅប្រទេសកម្ពុជា មានដាំសាវម៉ាវនៅលើផ្ទៃដីប្រមាណ ១៣១៨ ហិកតា ក្នុងនោះមានខេត្តៈ



- ✓. ខេត្តកំពង់ចាម=៤៦៨ ហិកតា
- ✓. ខេត្តកំពត = ៣៥០ ហិកតា
- ✓. កោះកុង = ៣៣៦ ហិកតា
- ✓. ក្រុងព្រះសីហនុ= ៩៦ ហិកតា
- ✓. ប៉ៃលិន = ៣៤ ហិកតា
- ✓. ក្រចេះ = ២៣ ហិកតា
- ✓. មណ្ឌលគិរី= ១២ ហិកតា

# ៣. លក្ខណៈរូបសាស្ត្រនៃដំណាំសាវម៉ាវ

## ៣.១. ដើមៈ

ដើមសាវម៉ាវ មានរាងជាពីរ៉ាមីតឈរ ដែលមានកម្ពស់មធ្យមចាប់ពី ១២-២៥ ម៉ែត្រឬអាចមានកម្ពស់រហូតដល់ទៅ ៤០ ម៉ែត្រ ចំពោះដើមដែលដុះចេញពីអំប្រីយ៉ុងគ្រាប់ផ្ទាល់។ ដើមមានលក្ខណៈបែកមែកពីដី កម្ពស់៤០-៦០សង់ទីម៉ែត្រ រាងមូល ធំទូលាយ សំបកនៃដើមមានពណ៌ត្នោត ឬប្រផេះចាស់។ ប៉ុន្តែចំពោះដើមបំបៅ ឬផ្សាំ មានកម្ពស់ប្រហែលពី ៧-១០ម៉ែត្រប៉ុណ្ណោះ ។



### ៣.២ ឫស:

ចាប់ផ្ដើមដុះមកព្រមៗគ្នា ជាមួយការលូតលាស់ របស់សរីរាង្គនៃដើម។ ទំហំ និងប្រវែងឫសរបស់ដំណាំសាវម៉ាវ អាស្រ័យទៅនឹងប្រភេទដី ដោយខ្លះមានប្រវែង៥០-១០០សង់ទីម៉ែត្រ ចំពោះឫសកែវ ចំណែក ឫសរយោងវិញមានប្រវែង ៤-៥ ម៉ែត្រ ដុះចាក់ពាសពេញផ្ទៃផ្នែកក្រោមដើម ។ ឫសមានតួនាទីស្រូបយកសារធាតុចិញ្ចឹមផ្សេងៗ ពីក្នុងដី ដើម្បីចិញ្ចឹមសរីរាង្គដើមផ្នែកខាងលើ ។



### ៣.៣. ស្លឹក:

ស្លឹករបស់សាវម៉ាវ មានលក្ខណៈដុះផ្លាស់គ្នា ហើយមានទំហំ បណ្ដោយពី ៥-២៨ សង់ទីម៉ែត្រ និង ទទឹង ២-១០.៥ សង់ទីម៉ែត្រ នៅផ្នែកខាងលើ មានភាពរលោង ឬមានរោមបន្តិចបន្តួច រីឯផ្នែកផ្ទៃស្លឹកខាងក្រោមសំបូរទៅដោយរោម ។

សរសៃ Vein មានជាលិកា ២ និង Vessel ទៅបង្កើតជាបណ្តាញ សរសៃពាស ពេញផ្ទៃស្លឹក



## ៣.៤. ផ្កា:



ផ្ការបស់សាវម៉ាវ មានលក្ខណៈជាចង្កោម នៅក្នុងពន្លកត្រង់ឆ្អឹតឡើងទៅលើ ពណ៌ច្រេះ ប្រវែង ១៥-២០ សង់ទីម៉ែត្រ ហើយផ្កាមានពណ៌ស លាយខៀវមានShort petioledapealous-fainly odorous ហើយស្រោបដោយត្រួយខ្លីៗយ៉ាងល្អ ។ Pedicels ឡើងមានពណ៌លឿង លាយខៀវ ហើយ Pubcscent មានលក្ខណៈក្រាស់ ចំណែក Caly x មានរាងដូចពែងដែល មានទងពី ៤-៦ ពណ៌សលឿង លាយខៀវ ហើយ Fomantose មានពណ៌ច្រេះនៅខាងក្រៅ និងស្រទាប់សពណ៌ខ្ចីនៅខាងក្នុង ។ ផ្កាមានត្របក Sepal ៤-៥ ច្រើនបំផុត ។

### ៣.៥. ផ្លែ:

ផ្លែសាវម៉ាវមានរាងមូល ឬអេលីប ប្រវែង និង ទម្ងន់ អាស្រ័យទៅតាមប្រភេទពូជ ចំពោះពូជខ្លះ ផ្លែមានប្រវែងរហូតដល់ទៅ ៧ x ៥ សង់ទីម៉ែត្រ មានទម្ងន់ចាប់ពី ២០-៩៥ ក្រាម ។ ផ្លែខ្ចី មានពណ៌ខៀវ ពេលទុំពណ៌លឿង ឬ ក្រហមផ្លែមានព្រួយយ៉ាងច្រើនព័ទ្ធជុំវិញផ្លែ "ព្រុយ មានប្រវែង ០.៥-២ សង់ទីម៉ែត្រ" ។



### ៣.៦. សំបក និង គ្រាប់ :

ក. សំបក (Paticap): មានកម្រាស់ពី ២៥ មីលីម៉ែត្រ ឡើងទៅ មានពណ៌សដូចគូថខ្យង និងមានសភាពស្ងួត ។

ខ. គ្រាប់ (Seed): សម្បូរទៅដោយជាតិអាមីឌុង ហើយក្នុងមួយផ្លែមានគ្រាប់តែមួយ ។ គ្រាប់ មានរាងសំប៉ែតទ្រវែង ឬដូចស៊ុត មានបណ្ដោយពី ២.៥-៣.៥ សង់ទីមែត្រ និងទទឹងពី ១-១.៥ សង់ទីម៉ែត្រ ។ គ្រាប់គ្របដណ្ដប់ដោយសាច់ពណ៌ស និង លឿង។





## ៤. លក្ខណៈបរិស្ថាន អាកាសធាតុ ដី សម្រាប់ដំណាំសាវម៉ាវ

### ៤.១. សំណើមបរិយាកាស

សាវម៉ាវដុះលូតលាស់ល្អ និងផ្តល់ទិន្នផលខ្ពស់នៅតំបន់ត្រូពិច ដែលមានអាកាសធាតុ ក្តៅហើយសើម ទទួលខ្យល់ដែលមានសំណើមបរិយាកាសគ្រប់គ្រាន់សម្រាប់ការធ្វើរស្មីសំយោគ។ គួរជៀសវាងការដាំដុះនៅ ជិតមាត់សមុទ្រពេក ព្រោះខ្យល់សមុទ្រអាច ធ្វើឱ្យឆាប់ស្ងួតជាលិកា សណ្តង់ផ្កា ហើយនិងក្តិបជ្រុះ ធ្វើឱ្យទិន្នផលថយចុះ ។

### ៤.២. ទឹកភ្លៀង

សាវម៉ាវ គឺជាដំណាំដែលត្រូវការទឹកភ្លៀងពីមធ្យម ទៅច្រើន សម្រាប់ការដុះលូតលាស់ ប៉ុន្តែវាមិនត្រូវការទឹកជោគជាំជាប្រចាំនោះទេ ព្រោះអាចបណ្តាលឱ្យកើតជំងឺរលួយឫស ។ បរិមាណទឹកភ្លៀងដែលសមស្របសម្រាប់ការដុះលូតលាស់របស់ដំណាំសាវម៉ាវ ចាប់ពី ២០០០ មីលីម៉ែត្រក្នុងមួយឆ្នាំ រហូតដល់ទៅ ៣០០០ មីលីម៉ែត្រក្នុងមួយឆ្នាំ ជាទូទៅមរិមាណទឹកភ្លៀងក្នុងកម្រិតនេះ គឺអំណោយផលដល់ការដុះលូតលាស់របស់ដំណាំសាវម៉ាវ ។

### ៤.៣. សំណើម

ដំណាំសាវម៉ាវ ជាដំណាំដែលត្រូវការចាំបាច់បំផុតនូវសំណើមបរិយាកាស ហើយដំណាំនេះគេច្រើនធ្វើការដាំដុះនៅដើមរដូវវស្សា ។ សំណើមដែលសមស្របសម្រាប់ការដុះលូតលាស់អាចពី ៦០-៨០% ។ ចំពោះដំណាក់កាលដុះពន្លក គឺពី ៥០-៦០% ចំណែកដំណាក់កាលចាក់ឫសកំណើតអាចត្រឹម៥០% និងជាពិសេសក្នុងដំណាក់កាលបង្កើត ផ្កា ក្តិប ប្រសិនបើមិនមានសំណើមសមស្រប នាំឱ្យដំណាំសាវម៉ាវជ្រុះក្តិប និងធ្វើឱ្យពូជអាចក្លាយ ។

### ៤.៤. សីតុណ្ហភាព

សាវម៉ាវ ត្រូវបានគេដាំនៅសីតុណ្ហភាព ១៥C° នៃខ្សែអេក្វាទ័រ ប៉ុន្តែជាធម្មតាសីតុណ្ហភាព ១២C° ជាមួយរយៈកម្ពស់ដល់ទៅ ៥០០-៧០០ ម៉ែត្រ នៃរយៈកម្ពស់

ធៀបនឹងនីវ៉ូទឹកសមុទ្រ ។ ហើយសីតុណ្ហភាពមធ្យមប្រចាំនៅតំបន់អាស៊ីអាគ្នេយ៍គឺ ២២-៣០C សមស្របក្នុងការដុះលូតលាស់ ។

### ៤.៥ ពន្លឺ

ក្នុងវគ្គដំណុះគ្រាប់ ដំណាំសាវម៉ាវមិនសូវត្រូវការពន្លឺប៉ុន្មានទេ ហើយចំពោះកូនទើបដាំ គឺទាមទារការគ្របជាការងារចាំបាច់ នៅពេលដែលមានពន្លឺថ្ងៃខ្លាំង។ គេត្រូវប្រើរយៈពេលពី ១០-១៥ ថ្ងៃ ប៉ុន្តែចំពោះកូនបបំបៅវិញគេគ្របរយៈពេលពី ២០-២៥ ថ្ងៃ ទើបល្អ ។ ដំណាំសាវម៉ាវត្រូវការពន្លឺពី ៥០-៦០% គឺគ្រប់គ្រាន់ ក្នុងការចាក់ឫស ។ប៉ុន្តែគួរប្រុងប្រយ័ត្ននៅរដូវវស្សា ដែលមានទឹកច្រើន ធ្វើឱ្យមានពន្លឺមិនគ្រប់គ្រាន់ ក្នុងការបំពេញសេចក្តីត្រូវការរបស់ដំណាំសាវម៉ាវ ពីព្រោះនៅក្នុងដីអាចជាំទឹក ឬដក់ទឹក ក្នុងផ្នែកណាមួយនៅផ្នែកផ្នែខាងក្រោមនៃឫស ធ្វើឱ្យដំណាំរលួយគល់ និងងាប់បាន។ ម្យ៉ាងវិញទៀតកុំឱ្យដីហាប់ពេក នាំឱ្យកាត់បន្ថយពន្លឺដែរ សម្រាប់ការលូតលាស់នៃឫស ។

### ៤.៦ ដី

#### ក. លក្ខណៈរូបសាស្ត្ររបស់ដី



ដំណាំសាវម៉ាវ ដុះលូតលាស់បានល្អនៅលើប្រភេទដីថ្មី ឬដីដែលទើបនឹងកាប់ឆ្ការួចដីល្បាយខ្សាច់លាយគ្រួស ឬ ដីឥដ្ឋតែស្រួយមានសារធាតុចិញ្ចឹមច្រើន និង ស្រទាប់ទីមួយធូរល្អដែលមាន pH ៥,៥-៦,៥ ។

## ៥. ពូជ

ពូជសាវម៉ាវមានច្រើនជាង២០០ ប្រភេទផ្សេងៗគ្នា ខុសគ្នាតែទំហំដើម ផ្លែ សាច់ គ្រាប់។ ក្នុងនោះពូជសំខាន់ៗមានដូចជា៖

- ពូជ Mahalika មានរស់ជាតិផ្អែម ផ្លែទុំពណ៌ក្រហម ទំហំផ្លែ បណ្តោយអាច

ពី ៤៣ រហូតដល់ ៥.១ សង់ទីម៉ែត្រ ទទឹងអាចពី ៣៥ - ៤៦ ស.ម រាងជាស៊ុត ឬទ្រវែង ហើយទម្ងន់ផ្លែអាចពី ២៩-៥៤ ក្រាម

✔. ពូជSeematjanមានរស់ជាតិផ្អែមផ្លែទុំពណ៌ក្រហមដិតទំហំផ្លែបណ្តោយអាចពី៤-៦ សង់ទីម៉ែត្រ ទទឹងផ្លែអាចពី ៣-២ សង់ទីម៉ែត្រ រាងទ្រវែងឬពងក្រពើ ហើយទម្ងន់ផ្លែអាចពី ៣៥-៥២ ក្រាម ។

✔. ពូជ Seenjonja មានរស់ជាតិផ្អែម ផ្លែទុំពណ៌ក្រហមព្រឿង ទំហំផ្លែបណ្តោយអាច៣៨, ៤,២០សង់ទីម៉ែត្រ និងទទឹងពី ២,៥-៣,៥ សង់ទីម៉ែត្រ មានរាងស្ទើរជាស៊ុត ហើយទម្ងន់ផ្លែអាចពី ១៨-២៣ ក្រាម។

✔. ពូជ Lappacum ដើមធំមធ្យម ទ្រនុងស្លឹកមានរោមរ៉ុយៗ នៅពីក្រោមសរសៃរួញ អង្កាញ់ខ្លាំង ។ មានដាំនៅប្រទេសថៃ ម៉ាឡេស៊ី កោះស៊ូម៉ាត្រា កោះ Java Kalimantan Philippines ។

✔. ពូជ Palleus "Hiern" ដើមមធ្យម ឬក្រោយមធ្យម ទ្រនុងស្លឹកតាមធម្មតា គ្មានរោម។ មានដាំច្រើននៅប្រទេសចិន ថៃ ឡាវ កម្ពុជា វៀតណាម ម៉ាឡេស៊ី Sumatra Kalimantan Philippines ខាងត្បូង Sulawesi។

✔. ពូជ Xamthioide Radlk ដើមធំមធ្យម ឬក្រោមមធ្យម ទ្រនុងស្លឹកមានរោមខ្លី ក្រាស់នៅពីក្រោម សរសៃសំបកអង្កាញ់បន្តិច។ មានដាំច្រើននៅBorneo។

### ៥.១ ការជ្រើសរើសពូជ :

ការជ្រើសរើសពូជ ជាកិច្ចការសំខាន់ ដែលកសិករទូទៅចាំបាច់ត្រូវយកចិត្តទុកដាក់ជាប្រចាំ។ ពូជល្អ ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

✔. ពូជដែលធន់ទ្រាំនឹងជំងឺសត្វល្អិត ការប្រែប្រួលអាកាសធាតុ

✔. ពូជដែលមានទំហំធំ ទុំស្រុះៗគ្នាល្អ

✔. ពូជដែលមានសំបកស្តើង សាច់ក្រាស់ ហើយសាច់មិនជាប់គ្រាប់

✔. ពូជដែលមានសោភ័ណ្ឌភាពល្អ មានភាពទាក់ទាញ និងមានរសជាតិឆ្ងាញ់

✔. ពូជដែលយកចេញមកពីដើមមេ មានសុខភាពល្អ

✓. ពូជដែលមានសាច់ពណ៌ស និងមិនសូវសម្បុរសរសៃ

✓. ពូជដែលមានដើមធំ និង ទទួលទិន្នផលច្រើនឆាប់ទទួលផលផ្លែ

ដើម្បីអាចឱ្យសាវម៉ាវចេញផ្កាតាម លក្ខណៈខាងលើ គេត្រូវធ្វើការសំរិតសំរាំងនូវពូជសាវម៉ាវ មុននឹងយកទៅដាំដុះ និងយកទៅធ្វើអាជីវកម្ម ។

### ៥.២. ការបន្តពូជរបស់ដំណាំសាវម៉ាវ :

ការបន្តពូជរបស់ដំណាំសាវម៉ាវ គេអាចធ្វើទៅបានពីរបៀបគឺ :

✓. ការបន្តពូជដោយគ្រាប់

✓. ការបន្តពូជដោយសរីរាង្គលូតលាស់

### ក- ការបន្តពូជដោយគ្រាប់

ដំណាក់កាលដំបូង ត្រូវជ្រើសរើសយកផ្លែសាវម៉ាវណា ដែលមានលក្ខណៈទុំល្អ ត្រូវបកសំបក និងយកសាច់ចេញទុកតែគ្រាប់ហាលសំដិលមួយយប់ ។ ចំពោះគ្រាប់ដែលធ្វើជាពូជ ត្រូវមានសំណើមទាបជាង ឬស្មើ ១៤% និង ដំណុះ៧៥%ទៅ ៨៥% ។



ដំណាក់កាលបន្ទាប់ ត្រូវរៀបចំថ្នាល ដោយមានធាតុផ្សំ ដូចជាជីលាមកសត្វ ផេះអង្កាម លាយជាមួយគ្នាផ្អាប់ទុកចោល រយៈពេលមួយខែ ទើបគេយកគ្រាប់ទៅបណ្តុះក្នុងថ្នាល ដែលមានផ្ទៃដី ១ ម៉ែត្រការ៉េអាចបណ្តុះបាន ១០០ គ្រាប់សាវម៉ាវ។

ការដាក់គ្រាប់បញ្ចៀតត្រូវដាក់ ផ្នែកចុងស្រួចចុះក្រោម ហើយគម្លាត ១០ សង់ទីម៉ែត្រ

ពីគ្នា ជំរៅពី១-២ មីលីម៉ែត្រ និងធ្វើការស្រោចទឹក ២ ដងក្នុងមួយថ្ងៃ ។

### ខ- ការបន្តពូជដោយសរីរាង្គ

### ❶ ការតភ្ជាប់ដើម ទៅនឹងមែកពូជ(បច្ចេកទេសបំបៅកូនសាវម៉ាវ) :

បច្ចេកទេសនេះ គឺជាការតភ្ជាប់មែករុក្ខជាតិមួយ ទៅរុក្ខជាតិមួយទៀត ដែលពួករុក្ខជាតិទាំងនេះស្ថិតនៅក្នុងអំបូរដូចគ្នា ។ វិធីសាស្ត្រនេះមានសារៈសំខាន់ ព្រោះគេអាចយកដើម ដែលមានលក្ខណៈធន់ជំងឺ សត្វល្អិតផ្លែល្អ ផ្តល់ទិន្នផលខ្ពស់ដែលជាតំរូវការ ។

- ✔. ត្រូវធ្វើការដាំដុះពូជល្អមានអាយុ ៤ឆ្នាំឡើងទៅសម្រាប់ជាមែកពូជតភ្ជាប់
- ✔. កូនសាវម៉ាវដែលត្រូវយកទៅបំបៅភ្ជាប់ត្រូវមានអាយុពី៤០-៥០ ថ្ងៃឬកម្ពស់ ពី ៥០-៧០ សង់ទីម៉ែត្រ ដែលបានយកមកពីថ្នាលបំប៉នមួយសម្រាប់ជាដើមទម្រ ។

**ដំណាក់កាលទីមួយ** : គេធ្វើការដកកូនពីថ្នាលបំប៉ននោះ មកកាត់ឫស២/៣ ចោល ធ្វើរបៀបនេះដើម្បីកុំឱ្យ វាស្រូបយកសារធាតុចិញ្ចឹមច្រើនពេក។ ក្រោយមកទៀត ត្រូវឆូតឫស ៤-៥ កន្លែងហើយ ជ្រលក់ទឹកអូសាវ៉ែ ទុកឱ្យស្ងួត រយៈពេល១៥ នាទី ទើបយកទៅលាបអរម៉ូន "សេរ៉ាទិច" មុនដាក់ថង់ ធាតុផ្សំក្នុងថង់មានកំទេចកំទីស្រកីដូង :

- ✔. នៅខែប្រាំងត្រូវដាក់ទឹកផ្សើម ហើយច្របាច់ឱ្យចេញទឹក
- ✔. នៅរដូវវស្សា ត្រូវដាក់ទឹកល្មមជៀសវាងទឹកច្រើននាំឱ្យរលួយឫស
- ✔. ផង់ដាក់ស្រកីដូងត្រូវមានទំហំ ៦ X ១២ សង់ទីម៉ែត្រ ហើយពេលញាត់កំទេចស្រកីដូងនោះ ត្រូវញាត់ឱ្យណែន ជៀសវាងការចូលខ្យល់ ។
- ✔. បន្ទាប់មក ទើបធ្វើការដាក់ដើមចូលក្នុងថង់ចងឱ្យណែន ហើយព្រលាត់មាត់ផង់ ជៀសវាងការដក់ទឹក ។

**ដំណាក់កាលទី ២:** ត្រូវកាត់ដើមត ជាចំណិតត្រសក់ កម្ពស់ពីគល់ប្រមាណ ២០-៣០ សង់ទីម៉ែត្រ ដោយប្រើកាំបិតយ៉ាងមុត ដើម្បីត្រៀមសម្រាប់យកទៅតត្រង់

មែកពូជដែលគេបានត្រៀមទុក ។

**ដំណាក់កាលទី ៣ :** ត្រូវយកកូនដែលត្រៀមរួចមកវាស់ នឹងមែកពូជ រួចចិត រាងបញ្ចិតចូលឱ្យសមល្មម និងកូនត "មែកពូជនោះត្រូវមានអាយុ ៤-៦ ខែ " ទើបល្អ ។

**ដំណាក់កាលទី ៤ :** យកកូនពូជដែលតនោះ ទៅដាក់ផ្ទាល់នៅនឹងមែកពូជ រួចចងថង់ឱ្យណែនទៅនឹងមែកពូជ ការពារកុំឱ្យវារមិលរួចទើបយកខ្សែប្លាស្ទីកឬបង់មិនស្អិត ពណ៌ខ្មៅ រុំឱ្យណែនលើមុខដំណរនោះ ។

**ដំណាក់កាលទី ៥ :** ក្រោយពីបញ្ចប់ការផ្សាំមែក ឬបំបៅ រយៈពេល ៣០-៤៥ ថ្ងៃ ក្រោយមកមក ឬអាចពិនិត្យមើលឫសក្នុងថង់ ដុះចេញមកមានពណ៌ត្នោត ទើបអាចយកទៅដាំបានល្អ ។

✓. ការបំបៅមែកលើដើមផ្ទាល់

✓. ត្រូវធ្វើនៅលើមែកដែលមានអាយុចាប់ពីមួយឆ្នាំ នៅត្រង់ចំណុចដែលគេចង់ឱ្យឫសដុះ ត្រូវលាក់សំបកប្រវែងពី ១៥-២០ សង់ទីម៉ែត្រ ដោយកុំឱ្យដល់សាច់ឈើ ។

✓. នៅកន្លែងដែលលាក់នោះ គេរុំខ្សែប្លាស្ទីក ដើម្បីកុំឱ្យសំបកថ្នាំងដុះឡើងវិញ ។ នៅលើផ្ទៃដែលគេលាក់នោះ អាចលាបសារធាតុសម្រួលការលូតលាស់ជុំវិញកន្លែងលាក់ និងលើកន្លែងលាក់ពី ២-៣ សង់ទីម៉ែត្រ ។

✓. សារធាតុសម្រួលការលូតលាស់ ត្រូវលាបបញ្ចូលជាមួយ Canoline លើមែកប្រវែង១ សង់ទីម៉ែត្រ ពីផ្នែកខាងក្រោមកន្លែងលាក់ និងផ្នែកខាងលើនៃកន្លែងលាក់ប្រវែង ២០ សង់ទីម៉ែត្រ ដោយមានធាតុផ្សំអាចម៍រណាកំទេចឈើល្អិត ឬដីដែលផ្សើម ស្មោសើម ។ គេត្រូវធ្វើការរុំបង់ស្អិត បញ្ឈរនៅលើមែកនៃបន្ទះប្លាស្ទីក គឺដើម្បីរក្សាសំណើម និងរំហួតទឹក ។

✓. ដើម្បីធ្វើការសំរួលដល់ការកាត់ចេញ ក្នុងរយៈពេលពី ៣០-៤៥ ថ្ងៃ ក្រោយមក គេលាក់ សើរៗនៅក្រោមកន្លែងដែលគេផ្សាំ ។ ១៥ ថ្ងៃ ក្រោយមក គេ

កាត់មែកផ្សាំនៅកន្លែងផ្សំលើកទីមួយ ។

✓. បន្ទាប់មកស្រាយស្បោងប្លាស្ទិចដោយដាក់កូនឈើថ្មីទៅក្នុងជើង ដើម្បីស្រួលថែទាំ ។ ហើយត្រូវដាក់ជើងក្នុងម្លប់ស្រោចទឹកឱ្យបានទៀងទាត់ កាលណាវាលូតលាស់ល្អ បើគេ បញ្ចេញឱ្យត្រូវថ្ងៃបន្តិចម្តងៗ។




*វិធីសាស្ត្រ ភ្ជាប់មែក*

## ៦. បច្ចេកទេសដាំដុះ

### ៦.១. ការជ្រើសរើសចម្ការ

ចំពោះផលិតកម្មដំណាំសាវម៉ាវ ការជ្រើសរើសចម្ការជាការងារចម្បង ដែលអាចឆ្លើយតប ឬសមស្របទៅនឹងបច្ចេកទេសដាំដុះដំណាំឈើហូបផ្លែ នាពេលបច្ចុប្បន្ននេះ ដើម្បីទទួលបានទិន្នផលគួរជាទីគាប់ចិត្ត ។ ការងារនៃការជ្រើសរើសចម្ការនេះ មុនដំបូង យើងត្រូវត្រួតពិនិត្យមើលទៅលើប្រភេទដី ថាដីណាសម្បូរដី

ជាតិ ឬដីដែលសម្បូរមមាគច្រើន ព្រោះសាវម៉ាវជាដំណាំដែលមានតម្រូវការជីជាតិច្រើន ម្យ៉ាងទៀតជាដំណាំត្រូវការសំណើមខ្ពស់ ។

ការជ្រើសរើសចម្ការ ជាទូទៅច្រើនធ្វើឡើងនៅក្បែរផ្ទះ ព្រោះងាយស្រួលក្នុងការថែទាំ ដូចជាធ្វើស្មៅ ស្រោចទឹក ការពារការបំផ្លាញពីសត្វល្អិតចង្រៃ ហើយអាចការពារបានពីការលួចបេះផ្លែសាវម៉ាវនៅពេលទុំ ។

ការពិនិត្យប្រូហ្វីលដី និង PH ដី កសិករគួរយកចិត្តទុកដាក់លើបញ្ហានេះ ព្រោះដំណាំសាវម៉ាវ ត្រូវការនូវប្រភេទដី ក្នុងកម្រិតមួយដែលសមស្រប សម្រាប់ការដុះលូតលាស់ និងផ្តល់នូវទិន្នផលខ្ពស់ ។ បន្ទាប់មក ធ្វើការត្រួតពិនិត្យមើលអំពីស្ថានភាពទីតាំងភូមិសាស្ត្រនៃទីកន្លែងដែលយើងចង់ធ្វើការដាំដុះនោះ ដោយពឹងផ្អែកទៅលើកត្តាដូចខាងក្រោម :

✓. ត្រូវនៅជិតប្រភពទឹក ដើម្បីងាយស្រួលក្នុងការស្រោចស្រព ព្រោះសាវម៉ាវជាដំណាំឈើហូបផ្លែត្រូវការទឹកជាចាំបាច់ បើសិនគ្មានទឹកសម្រាប់ស្រោចស្រពនៅរដូវប្រាំងឱ្យបានគ្រប់គ្រាន់ទេនោះ នៅដំណាក់លូតលាស់ដំបូងអាចធ្វើឱ្យការលូតលាស់របស់ដើមមានភាពយឺតយាវ ដែលជាហេតុបណ្តាលឱ្យការផ្តល់ផ្លែមានភាពយឺតយ៉ាវដែរ ។

✓. មានបណ្តាញផ្លូវគមនាគមន៍ល្អ ងាយស្រួលក្នុងការដឹកជញ្ជូនផលិតផលទៅកាន់ទីផ្សារ

### ក. ការរៀបចំដី :

✓. តំបន់ព្រៃ : ចំពោះដីដែលជាតំបន់ព្រៃ ត្រូវធ្វើការកាប់ឆ្ការព្រៃ និងធ្វើការឈូសឆាយសម្អាតស្មៅ រួចប្រមូលយកទៅដុតចោល ។ ក្រោយពីដុតចោលបានរយៈពេល២-៣ថ្ងៃ ត្រូវភ្ជួរលុបដី ។ ការភ្ជួរបៀបនេះ ធ្វើឱ្យបានជម្រៅ ២០-៣០ ស.ម ដើម្បីយកឫសរបស់ដើមឈើចេញ ព្រោះវាអាចរំខានដល់ការដុះឫស របស់ដំណាំសាវម៉ាវ ។

## ការប្រើប្រាស់ជី៖

ជាទូទៅយើងអាចដាក់ជីធម្មជាតិក្នុងកម្រិត ១០-២០ គីឡូក្រាមលើដំណាំសាវមាវ ១ ដើម ក្នុងរយៈពេល១ឆ្នាំ និងជីគីមីក្នុងកម្រិតអាសូត=២០០g P= ២៥ g, K= ១០០g ក្នុង១ដើមក្នុង១ឆ្នាំ។

✔. ចំពោះដំណាំសាវម៉ាវក្នុងដំណាក់កាលទើបចេញផ្លែ ឬកំពុងផ្លែត្រូវដាក់ជីគីមីក្នុងកម្រិត N=២០០g P=២៦g និង K= ១៣០g សម្រាប់ដំណាំសាវម៉ាវមួយដើមក្នុង១ឆ្នាំ។

✔. ចំពោះកូនសាវម៉ាវនៅក្នុងថ្នាលបណ្តុះ កម្រិតជីត្រូវប្រើ N= ២០g, $P_2O_5$ = ២០g និង$K_2O$ លាយជាមួយសារធាតុផ្សេងៗទៀត ដោយយោងទៅតាមអាយុ ពេលវេលា និងការណែនាំឱ្យប្រើប្រាស់។

បន្ទាប់មកធ្វើការបាចកំបោរ រួចហាលដីរយៈពេលពី ៧-១០ថ្ងៃ លុះក្រោយមកទើបប្រើជី ១៨:៤៦,00 ចំនួនពី ១៥០-២០០គីឡូក្រាម ក្នុងមួយហិកតា មុនពេលភ្ជួរត្រឡប់លើកទី២ ។ ការភ្ជួរដីនេះ ត្រូវធ្វើឡើងឱ្យបានច្រើនសារ មុនពេលដាំ ព្រោះអាចជួយឱ្យដីមានលក្ខណៈផុសល្អ និងអាចធ្វើឱ្យកាកសំណល់ដែលក្ររលួយ មានកប់ក្នុងដី នឹងងាយរលួយពុកផុយ ជាពិសេសទៅទៀត គឺដើម្បីការពារមិនឱ្យដក់ទឹក ក៏ដូចជាការពារជំងឺរលួយគល់ផងដែរ ។



✓. ចំពោះដីចម្ការនៅតាមជំរាលភ្នំ គឺគេមិនធ្វើការឈូសឆាយទេ ពោល គឺគេធ្វើការជីករណ្តៅ យកនៅត្រង់ចំណុចដែលត្រូវដាំដុះតែម្តង ។ ម្យ៉ាងវិញទៀត គេអាចប្រើវិធីលួសឆាយរាងដូចកាំជណ្តើរ ធ្វើរបៀបនេះដើម្បីការពារការហូរច្រោះ ប៉ុន្តែវិធីនេះត្រូវចំណាយថវិកាច្រើន ។

ខ. ពេលវេលាដាំដុះ : នៅតំបន់ទឹកឈូ ក៏ដូចតំបន់ដទៃទៀត ដែលប្រកបរបរ ដាំដុះដំណាំឈើហូបផ្លែ ច្រើនធ្វើឡើងនៅដើមរដូវវស្សា ព្រោះ ថានៅរដូវវស្សាសម្បូរ ទៅដោយទឹកគ្រប់គ្រាន់ មិនបាច់ធ្វើការស្រោចស្រព ។

ចំពោះរដូវប្រាំងចាំបាច់ត្រូវធ្វើការស្រោចស្រព ឱ្យបានទៀងទាត់ជាពិសេស ក្នុងដំណាក់កាលដំណាំសាវម៉ាវកំពុងរៀបចេញផ្កា ឬកំពុងចេញផ្កា។

### ៦.២. វិធីសាស្ត្រដាំកូនសាវម៉ាវ

នៅតំបន់នេះក៏ដូចតំបន់កសិកម្មដទៃទៀតដែរ ពោលគឺមុនដំបូងសាវម៉ាវ គេត្រូវធ្វើការជីករណ្តៅនៅចំកន្លែង ដែលគេជ្រើសរើសទុកជាមុន ។

វិធីដាំកូនក្នុងរណ្តៅ ត្រូវបានរៀបចំឡើងរយៈពេលពី ២ ទៅ ៣ ថ្ងៃមុននឹង យកកូនដាំ ។ ទំហំនៃរណ្តៅនៅតំបន់នេះ គេនិយមជីកទំហំរណ្តៅពី ១x១x១ ម៉ែត្រ និងបាតរណ្តៅពី ០.៨-១ ម៉ែត្រ រាងការ៉េ ៤ ជ្រុង ហើយជម្រៅនៃរណ្តៅពី ៥០-៧០ សង់ទីម៉ែត្រ ។ ចំណែកចន្លោះជួរ និងចន្លោះរង គឺឃ្លាតពីគ្នា ៨x៨ ម៉ែត្រ៨x៦ម៉ែត្រ ឬ១០x១០ ម៉ែត្រ អាស្រ័យទៅតាមប្រភេទដី និងតំបន់ដាំដុះ។ ការជីករណ្តៅនេះ គឺគេយកដីស្រទាប់លើដាក់មួយដុំ និងស្រទាប់ក្រោមដាក់មួយដុំដូចគ្នា បន្ទាប់មក ទៀត យកជីអាចម៍គោចំនួន ២ បង្គី ផ្នែកខាងលើនោះ ដាក់ទៅបាតរណ្តៅ ហើយ ធ្វើការដាក់បន្ត(១៥-៤០ គីឡូក្រាម) មកលាយច្របល់ជាមួយដីស្រទាប់លើរហូត ដល់មានកម្រាស់ប្រហែល ២/៣ នៃមាត់រណ្តៅ ដង់ស៊ីតេកូនដំណាំអាចពី ២០០-២៥០ ដើម ក្នុង១ហិកតា។

មុនពេលយកកូនទៅដាំក្នុងរណ្តៅ ត្រូវធ្វើការត្រួតពិនិត្យមើលលើកូនសាវ ម៉ាវណាដែលមានសភាពរឹងមាំ មិនកើតជំងឺ និងស្លាកស្នាមសត្វស៊ី មានត្រួយចាស់

មួយជួរនៅចុងក្រោយបង្អស់ ឫសបែកខ្នែងល្អ ហើយគូថថង់ដាក់កូនសាវម៉ាវ ពុំមានលក្ខណៈរៀចរ៉ែចឡើយ ។ ក្រោយពីការជ្រើសរើសកូនសាវម៉ាវរួចរាល់មក គេត្រូវយកមកឆៀលគូថថង់ដោយប្រើកាំបិត ហើយធ្វើយ៉ាងណា ដាក់កូនទៅក្នុងរណ្តៅថ្មៗ ឱ្យមានជំហរត្រង់ល្អ ហើយខ្ពស់ ពីមាត់រណ្តៅប្រហែល ១០ សង់ទីម៉ែត្រ និងធ្វើការតម្រង់កូនឱ្យត្រង់នឹងកូនដទៃទៀត ។



*កូនសាវម៉ាវអាយុបាន៦ខែបន្ទាប់ពីដាំ*

បន្ទាប់ពីរៀបចំស្រេចបាច់មក ទើបធ្វើការវះថង់ផ្នែកចំហៀង ពីក្រោមទៅលើ ដោយប្រុងប្រយ័ត្ន ធ្វើយ៉ាងណាកុំឱ្យបែកដីក្នុងថង់ ។ ក្រោយមក លុបដីដែលនៅសល់ទៅក្នុងរណ្តៅ ដោយមិនឱ្យដល់ស្នាមតភ្ជាប់ ។ បន្ទាប់មកបោះបង្គោលឫស្សីនៅក្បែរកូនសាវម៉ាវ ដែលទើបនិងដាំដោយចងផ្តោបទប់ ដើម្បីកុំឱ្យខ្យល់បក់រង្វើ រំខានដល់ការលូតលាស់របស់កូនដំណាំ និងធ្វើការពូនគល់ កូនសាវម៉ាវ ព្រមទាំងស្រោចទឹកឱ្យបានជោគជាំបន្តិច ។

កូនសាវម៉ាវដែលទើបនឹងដាំ គេត្រូវធ្វើរបាំងទប់ទល់នឹងកម្តៅថ្ងៃ សំណាញ់ស្លឹករុក្ខជាតិផ្សេងៗ ព្រោះកូនដែលទើបនឹងដាំ មិនសូវត្រូវការពន្លឺព្រះអាទិត្យខ្លាំងទេ ។ ចំពោះកូនសាវម៉ាវ ដែលបានមកពីការសាកត្រួយតភ្ជាប់មែក ត្រូវមើលការលូតលាស់របស់កូននោះ លុះត្រាតែ វាមានលក្ខណៈរឹងមាំ ទើបអាចស្រាយថ្មុំថង់ប្លាស្ទិកនៅចំកន្លែងទាំងនោះ ឬចាប់ពីដាំមករយៈពេលពី ២០-៣០ ថ្ងៃ ទើបអាច

ស្រាយនៃចំណុចផ្សាំបាន ។ ពេលវេលានៃការដាំកូនប្រព្រឹត្តនៅពេលល្ងាច ឬព្រឹកព្រលឹម ព្រោះវាមិនសូវក្តៅ ដែលជាហេតុនាំឱ្យកូនមិនសូវស្រពោន ។

## ៧. ការថែទាំ

ការថែទាំសម្អាតស្មៅ ធ្វើយ៉ាងញឹកញាប់ក្នុងរយៈពេល ៤ ឆ្នាំដំបូង បន្ទាប់ពីដាំ ហើយត្រូវធ្វើ ១-២ ដងជាមធ្យមក្នុងមួយឆ្នាំ ។ បើយកល្អ បន្ទាប់ពីធ្វើស្មៅបានល្អហើយ ត្រូវយកចំបើង ស្លឹករុក្ខជាតិ គ្របគល់ និង ជុំវិញមាត់មធ្យម ក្នុងមួយរណ្តៅ ដើម្បីរក្សាសំណើមបានយូរ ហើយត្រូវបាញ់ថ្នាំគីមីបំពុលការពារសត្វល្អិតនិងជំងឺ ក្នុងករណីដែលវាវាតត្បាតខ្លាំង ។

### ៧.១ ការកាត់កែងមែកៈ

✔ ត្រូវកាត់ចុងកណ្តាល "ក្តិចត្រួយ" ដើម្បីឱ្យមែកបែកខ្នែងខាង ហើយជ្រើសរើសមែកខ្នែង ដូចពោលទុកប្រមាណ ៣-៤ មែក ដោយជ្រើសរើសមែកល្អ ។ ដង្កាបទូលាយ ក្នុងកំឡុងឆ្នាំដំបូង កុំឱ្យពន្លកដើមដុះប្រណាំងនឹងត្រួយពូជល្អ។ បើមែកបែកត្រូវក្តិចចោលភ្លាម នៅបរិវេណគល់កម្ពស់ពី ៤០-៦០ សង់ទីម៉ែត្រ មិនត្រូវទុកមែកទេ ករណីមែកពូជមានខ្នែងសមស្រប មិនត្រូវកាត់ត្រួយកណ្តាលចេញឡើយ ។

✔ ក្នុងឆ្នាំទី ២-៤ ទុកឱ្យមែកខ្នែងដែលជ្រើសរើសដុះដល់ផុត តែបើមានមែកខ្នែងតូច បែកពីមែកខ្នែងធំណែនក្រាស់ពេក ត្រូវកាត់មែកខ្នែងតូចនោះចេញខ្លះ គឺត្រូវកាត់មែកកូនមានបង្កាប កូនមែកតូចដែលដុះចេញត្រួតគ្នា កាត់មែកក្រោមចេញ ឬមែកដុះផ្នែកខាងក្នុងច្រើន គេធ្វើការកាត់មែកពួកនេះចេញមុនដាក់ជីលើកទី ២ ។

✔ កាត់មែកដែលមានជំងឺ រហែកបាក់ងាប់ មែកបំពង់ នៅពេលក្រោយប្រមូលផលរួចរាល់ហើយ ។ បើបានអនុវត្តការតាក់តែងមែក តាំងពីឆ្នាំដំបូងមកក្នុងឆ្នាំបន្ទាប់ ត្រូវធ្វើការតាក់តែងមែកត្រឹមតែបន្តិចបន្តួចប៉ុណ្ណោះ ។

✔ បើទ្រង់ទ្រាយដើមណែនពេក ពន្លឺថ្ងៃចាំងចូលមិនគ្រប់គ្រាន់ ត្រូវតាក់តែងមែកខ្នែងតូច ដែលដុះជិតគ្នាច្រើនពេកបន្ថែមទៀត ការកាត់តាក់តែងមែកនេះចេញ

ដើម្បីឱ្យមានពន្លឺថ្ងៃចាំងច្រើនបន្តិច ។

✔ បន្ទាប់ពីកាត់តែងមែករួចហើយ ត្រូវលាបកំបោរ ឬថ្នាំការពារមេរោគផ្សេងៗ នៅកន្លែងមុខដែលកាត់ ដើម្បីការពារកុំឱ្យមេរោគឆ្លងរាតត្បាត ។

### ៧.២ ការស្រោចស្រព:




*ដើមមិនទាន់ធ្វើការកាត់តែងមែក*



*ដើមបានធ្វើការកាត់តែងមែករួច*

កូនសាវម៉ាវដែលទើបនឹងធ្វើការដាំដុះ ត្រូវការទឹកដើម្បីជំរុញឱ្យការដុះលូតលាស់ ។ នៅរដូវប្រាំង ការស្រោចស្រពមានសារៈសំខាន់ណាស់ ដោយយ៉ាងហោចណាស់ ក៏ក្នុង ១ អាទិត្យបានម្តងដែរ ប៉ុន្តែចំពោះ កូនដែលយកមកពីការផ្សាំ ត្រូវស្រោចទឹក ៣ ថ្ងៃម្តង ។ ការស្រោចស្រពនេះ ត្រូវធ្វើឡើងយ៉ាងទៀងទាត់ក្នុង រយៈពេល ១-២ ឆ្នាំដំបូង ។ ប៉ុន្តែនៅតំបន់ទឹកឈូ នៅរដូវវស្សាពួកគេមិននិយមធ្វើការស្រោចទេ ព្រោះជាតំបន់មានភ្លៀងធ្លាក់ច្រើន ។នៅពេលដែលដំណាំសាវម៉ាវកំពុងចាប់ផ្តើមចេញផ្កា ឬ ក្តឹប បើមានការខ្វះខាតទឹកនោះ វានឹងបណ្តាលឱ្យផ្កា ស្វិតស្រពោន ហើយជ្រុះពីទងតែម្តង ។ ម្យ៉ាងវិញទៀត ទឹកពុំគ្រប់គ្រាន់ វាតែងតែមានឥទ្ធិពលដល់ការលូតលាស់របស់ដំណាំដូចជា ធ្វើឱ្យដើមស្រពោន ជ្រុះស្លឹក ឬអាចដល់ងាប់តែម្តង នៅពេលដែលខ្វះទឹកក្នុងរយៈពេលយូរ ។ ទឹកជាសារធាតុសំខាន់បំផុតក្នុងការបង្កើតទិន្នផល ផ្លែផ្កា ។

ចំពោះប្រព័ន្ធស្រោចស្រព នៅក្នុងចម្ការរបស់កសិករ គឺត្រូវបានរៀបចំឡើងតាមបែបផែនផលិតកម្មទំនើប ដោយប្រើប្រាស់បំពង់ទុយោជាខ្សែងបន្តពីអាងស្តុកទឹកធំ មកបែងចែកតាមចន្លោះគុម្ពរបស់ដើមសាវម៉ាវ។ ការស្រោចស្រពនេះ ប្រព្រឹត្តទៅនៅរដូវប្រាំង ពោលគឺស្រោចទឹកក្នុងមួយអាទិត្យម្តង ចំនួន ១២០ - ១៥០ លីត្រ ក្នុងមួយដើម។ ប្រភពទឹកនេះទទួលបានមកពីទឹកហូរធ្លាក់លើភ្នំ ដោយគេធ្វើការរៀបចំអាងស្តុកទឹកនៅចង្កេះភ្នំ ហើយបញ្ជូនបន្តមកអាងស្តុកធំមួយ ដែលមានទំហំបណ្តោយ៦០ ម៉ែត្រ ទទឹង៤ ម៉ែត្រ ជម្រៅ ៣,៥ ម៉ែត្រ រួចស្រោចស្រពពេញផ្ទៃចម្ការតែម្តង ។



*អាងស្តុកទឹកសម្រាប់ធ្វើការស្រោចស្រព*

### ៧.៣ ការប្រើប្រាស់ជីៈ

នៅក្នុងការដាក់ជី គឺអាស្រ័យទៅតាមប្រភេទដី ដូច្នេះយើងត្រូវធ្វើការវិភាគដីជាមុនសិន ដោយយើងយកសំណាកដីកន្លែងដាំដុះនោះ ទៅធ្វើការវិភាគរកសារធាតុចិញ្ចឹមដែលមាននៅក្នុងដីស្រាប់ លទ្ធផលនៃការវិភាគជាប្រយោជន៍ដល់ការសម្រេចចិត្តមុនប្រើប្រាស់ជីបន្ថែម។ ការដាក់ជីត្រូវអនុវត្តដូចតទៅនេះ :

- ✔ ធ្វើការដាក់ជីក្រោយពីការតាត់តែងមែករួច
- ✔ ដាក់ជីព្រមទាំងសម្អាតគល់ គឺជម្រះស្មៅដែលនៅជុំវិញក្រោមដើមឱ្យបានស្មើល្អ ព្រោះជីនិងបំផុសដី ដែលនៅផ្នែកក្រោមដើម ឬពួនគល់និងធ្វើការកាប់ឆាយដីក្នុងជម្រៅ១០-១៥ សង់ទីម៉ែត្រខាងក្រោមដើម ឱ្យបានទំហំធំ ស្មើនឹងមែកបែកសាខារបស់ដើមសាវម៉ាវ រួចធ្វើការបាចជីគីមីនៅជុំវិញនោះ ។ វិធីសាស្ត្រនេះ

ចំណាយកម្លាំងពលកម្មច្រើន ប៉ុន្តែជួយបន្ធូរបន្ថយនូវការបាត់បង់ជីតាមរយៈខ្យល់ និងធ្វើឱ្យជីរលាយសព្វពាសពេញផ្ទៃផ្នែកក្រោមដើម ។

ចំពោះជីលាមកសត្វវិញ គេធ្វើតាមវិធីផ្សេង ដោយគេជីករណ្តៅនៅផ្នែកក្រោមដើម រួចដាក់លាមកសត្វចូលតែម្តង ក្នុងមួយដើមបួនរណ្តៅ ក្នុងមួយរណ្តៅ ១៥-២០ គីឡូក្រាម ។

✔ ដាក់ជីលាមកសត្វមុនសិន ទើបដាក់ជីគីមីតាមក្រោយ

✔ គួរដាក់ជីក្នុងបរិវេណខាងក្រោមដើម ជុំវិញឱ្យបានសព្វល្អ និងឃ្លាតពីគល់ប្រវែងពី៣០- ៥០ សង់ទីម៉ែត្រជុំវិញដើម។ ការប្រើប្រាស់ជីនេះ ត្រូវដាក់ដោយយោងទៅតាមចំនួន និងពេលវេលាដូចតទៅ :

✔ នៅពេលដាំកូនដំបូង ដាក់ជីលាមកសត្វចំនួន ២០ គីឡូក្រាម/១ដើម

✔ បន្ទាប់ពីដាំបាន ៧-១០ ថ្ងៃ ដាក់ជី ១៥.១៥.១៥ ចំនួន១០-១៥ ក្រាមក្នុងមួយដើម ។

✔ បន្ទាប់ពីដាំបាន ២-៣ខែ ដាក់ជី ១៥.១៥.១៥ ក្នុងកម្រិត០.៥-១ គ.ក្រ



*ជីសរីរាង្គ*




*ជីគីមី ១៥.១៥.១៥*

ក្នុងមួយដើម។

✓ និងចាប់ពីឆ្នាំទីមួយឡើងទៅ គឺដាក់ជី ១៥.១៥.១៥ ចំនួន ១-២ គ.ក្រ និងជីលាមកសត្វ ១៥-២០ គីឡូក្រាម/ដើម ដាក់របៀបនេះ រហូតដល់ឆ្នាំទី ៤ឬ៥

✓ ហើយនៅឆ្នាំដែលចាប់ទទួលទិន្នផល ការដាក់ជីលើដំណាំសាវម៉ាវ ត្រូវធ្វើឡើងពីរដងក្នុងមួយឆ្នាំ ។

✓ ដាក់ជីគីមីរៀងរាល់ឆ្នាំ ពោលគឺដាក់នៅពេលប្រមូលផលរួច និង ធ្វើការសម្អាតគល់ កាត់តែងមែកដោយដាក់១-៣ គីឡូក្រាម ក្នុងមួយដើម អាស្រ័យទៅតាមប្រភេទដើម តូចឬធំ។

✓ ធ្វើការដាក់ជីលាមកសត្វ ១ ឆ្នាំម្តង ដោយដាក់តាមរបៀបជីករណ្តៅក្នុង ១ ដើម ៤ រណ្តៅ ហើយ ៤ រណ្តៅត្រូវដាក់ពី ៦០-៨០ គីឡូក្រាម នៅដើមរដូវវស្សា ចំនួនជីគីមីដែលដាក់ម្តងៗ គឺយោងទៅលើទំហំដើម ដោយធ្វើការវាស់វែងពីគល់ដើមមកជាយ ទំហំដើមជា ម៉ែត្របានប៉ុន្មាន? គឺចំនួនជីគីមីដែលត្រូវដាក់ជា គ.ក្រ មានដូចជា :

✓ ចំងាយពីគល់ដើមដល់ជាយមែក១ម៉ែត្រដាក់ជី ១ គីឡូក្រាម

✓ ចំងាយពីគល់ដើមដល់ជាយមែក ២ម៉ែត្រ ដាក់ជី ២ គីឡូក្រាម

✓ ចំងាយពីគល់ដើមដល់ជាយមែក ៣ ម៉ែត្រ ដាក់ជី ៣ គីឡូក្រាម

## ៨. កត្តាចង្រៃលើដំណាំសាវម៉ាវ

### ៨.១. សត្វល្អិត

សត្វល្អិតដែលធ្វើការរាតត្បាតនៅលើដំណាំសាវម៉ាវ ហើយតែងជួបប្រទះជាញឹកញាប់នោះមានដូចជា :

**ដង្កូវចោះដើម :** ជាដង្កូវដែលចោះស៊ីដើម និងមែកអាចធ្វើឱ្យដើម និងមែកសាវម៉ាវងាប់បាន ។ ពពួកនេះច្រើនរាតត្បាតធ្ងន់ធ្ងរនៅរដូវក្តៅ ដោយធ្វើការស៊ីឡោមព័ទ្ធមែក បណ្តាលឱ្យស្រពោន ឬក៏ងាប់ ។

✓ ប្រជាករនៃមេរបស់វា" Bectle" អាចកាត់បន្ថយដោយការអង្រួនមែក

ហើយប្រមូល យកទៅកម្ទេចចោលនូវពពួកដង្កូវពេញវ័យដែលធ្លាក់មក ។ មែកណាមានហ្វូងរបស់វារស់នៅច្រើន គួរតែប្រមូលដុតចោលដើម្បីកម្ចាត់ពងរបស់វា ។

**វិធានការការពារ និង ព្យាបាល**

ត្រូវបាញ់ថ្នាំឌីទ្រីន ប្រភេទ ៥% ដោយលាយផ្សំជាមួយទឹក ។ តែបើវាចោះស៊ីជារន្ធវិញ ត្រូវប្រើថ្នាំ ហ្វូម៉ូកេស ជ្រលក់និងសំឡី ហើយញាត់ចូលទៅក្នុងរន្ធនោះរួចញ៉ុកដីឱ្យណែន ពេលនោះ ចំហាយរបស់ថ្នាំនេះ និងហើរចូលទៅបំពុលដង្កូវនៅផ្នែកខាងក្នុង ។

**ដង្កូវស៊ីស្លឹក** : ជាប្រភេទដង្កូវម្យ៉ាង ដែលកើតចេញពីពពួកមេអំបៅហើយវាស៊ីបំផ្លាញផ្នែកស្លឹក ដែលទើបនឹងលូតលាស់ ដើម តូច-ធំ។ លក្ខណៈរូបរាងរបស់ដង្កូវ មានទំហំ ២០ សង់ទីម៉ែត្រ ពណ៌ឆ្នោតចាស់ ។ បន្ទាប់ពីវាស៊ីបំផ្លាញស្លឹកវាបន្សល់ទុកនូវស្នាមក្រឆេញក្រឆូញ ជួនកាលឡើងមូល ក្រោយមកកន្លែងដែលវាស៊ីបំផ្លាញ ប្រែជាពណ៌លឿងត្នោតចាស់ ។ ដង្កូវនេះមិនបណ្តាលឱ្យដើមងាប់ទេ ប៉ុន្តែវាគ្រាន់តែធ្វើឱ្យស្លឹកបាត់បង់ទ្រង់ទ្រាយ ថយចុះនូវលទ្ធភាពនៃការធ្វើរស្មីសំយោគ

**វិធានការការពារ និង ព្យាបាល :**



មធ្យោបាយបំផ្លាញដង្កូវនេះ គឺគេត្រូវបាញ់ថ្នាំ ម៉ាឡាចុង ។

**ក្រាម៉ៃ** : សត្វល្អិតនេះវានឹងបឺតជញ្ជក់យកសារជាតិទឹកដែលបញ្ជូនទៅចិញ្ចឹម

តាមទងផ្កា វាអាចធ្វើឱ្យផ្កាមិនជាប់រហូតដល់ជ្រុះអស់ ព្រោះវាខ្វះជាតិទឹកបញ្ជូនទៅចិញ្ចឹមផ្កា ។

**វិធានការការពារ និង ព្យាបាល :**

ត្រូវប្រើថ្នាំបាញ់ ធីលទ្រីន ដោយធ្វើការបាញ់រៀងរាល់ ៥ ថ្ងៃម្តង ឬ ១០ ថ្ងៃម្តង ។

**កណ្តៀរ :** ជាប្រភេទសត្វល្អិត ធ្វើការបំផ្លាញនៅផ្នែកគល់ និង ដើមដោយធ្វើសំបុកផ្ទាល់ នៅនឹងដើម អាចបណ្តាលឱ្យរបើកសំបករបស់ដើម ដែលជាហេតុធ្វើឱ្យមានភាពងាយស្រួលក្នុងការចូល រាតត្បាតរបស់ពពួកបាក់តេរី ។ ហើយពពួកសត្វទាំងនេះ អាចបង្កឱ្យដើមសាវម៉ាវទាំងមូលរងគ្រោះថ្នាក់ខ្លាំង នៅពេលវាធ្វើសំបុកនៅនឹងគល់ អាចបណ្តាលឱ្យពុកគល់ ឬជួលដើមតែម្តង ។

**វិធានការការពារ និង ព្យាបាល :**

វិធីទប់ស្កាត់ទៅនឹងសត្វកណ្តៀរស៊ីគល់នេះ គឺគេត្រូវតែប្រើថ្នាំ Fungicide ចំនួន ៧ កញ្ចប់លាយជាមួយទឹក១៥00 លីត្រ និងលាយជាមួយថ្នាំ Malathion ចំនួនមួយដប ដោយបាញ់ក្នុងមួយអាទិត្យម្តង តែនៅរដូវវស្សា ។

**ការបំផ្លាញដោយសត្វដង្កូវរុយ:** ការបំផ្លាញដោយសត្វដង្កូវរុយច្រើនកើតមាននៅលើផ្លែ ។ ជាដំបូងរុយពងដាក់លើសំបក ផ្លែសាវម៉ាវ ៥-៦ថ្ងៃក្រោយមកកូនដង្កូវញាស់ ហើយស៊ីបំផ្លាញសាច់នៅក្នុងផ្លែ ។ ប្រហែលជា ៥0 % ដោយរងនឹងការបំផ្លាញនេះ ផ្លែត្រូវខូចខាតហើយត្រូវជ្រុះមុនពេលទុំ ។

**វិធានការការពារ និង ព្យាបាល:**

ត្រូវបេះផ្លែដែលរងការបំផ្លាញនោះ ដុតចោល ឬបាញ់ថ្នាំការពារជាមុនចំពោះផ្លែ ខ្វីដែលការបំផ្លាញដោយប្រើថ្នាំគីមី ម៉ាឡាចុង ។

### ៨.២. ជំងឺ

**ជំងឺងាប់ជាលិកាន៏ែ** "Vein Neurosis" គឺប្រភេទជំងឺបាក់តេរី ដែលបង្កឡើងដោយ "Xantho-monosnophiliae Bar" បំផ្លាញស្លឹកកូនរុក្ខជាតិ និងដើមដែលមាន

ផ្លែ ។ នៅតាមគែមស្លឹករបួសមុនដំបូង គឺបែកញើសហើយមានពណ៌ខ្មៅនៅលើផ្ទៃស្លឹកសងខាង ។ របួសក៏ប្រែជាពណ៌ត្នោតភ្លាម ក្រោយមកស្ងួត ហើយព័ទ្ធជុំវិញដោយពណ៌លឿងខ្ចី នៅពេលឆ្លងចូលដល់សរសៃវ៉ែន "Voin" ប្រែជាពណ៌ត្នោត ហើយបង្កើតលទ្ធភាពងាប់ជាលិកា ។ ក្នុងករណីដែលកើតនៅ កន្លែងបណ្តុះកូនគួរបាញ់ថ្នាំយូរៗម្តង ។

**វិធានការការពារ និង ព្យាបាល :**

ប្រើថ្នាំលាយ Bordeaux ៤-៤-៥០ ។

**ជំងឺអុជស្លឹក :** បង្កឡើងពីពពួកផ្សិតឈ្មោះ PhomopsisdurinnisSyd រោគសញ្ញាដំបូងរបស់ជំងឺនេះ គឺសម្គាល់ដោយសារស្នាមអុជមួយ ដូចម្ជុលដែលផ្ទែកអុជនីមួយៗ ព័ទ្ធដោយខ័ណ្ឌពណ៌លឿង ។ ស្នាមអុជនេះពង្រីកទៅជាពងក្រពើពណ៌សដូចផេះ ទៅជាចំណុចពណ៌ត្នោតខ្ចី ដែលមានអង្កត់ផ្ចិតប្រវែង១មីលីម៉ែត្រ ដោយមានរឹមពណ៌ត្នោតចាស់ ព័ទ្ធជុំវិញដោយវ៉ែនពណ៌លឿង បន្ទាប់មក ស្នាមអុជនោះមកកើតពេញផ្ទៃខាងលើរបស់ស្លឹកសាវម៉ាវ ។

**វិធានការការពារ និង ព្យាបាល :**

ចំពោះសាវម៉ាវពេញវ័យដែលមិនសូវមានស្លឹក មិនចាំបាច់មានវិធានការអ្វីទេ ប៉ុន្តែចំពោះកូនសាវម៉ាវ ដែលមានកើតជំងឺនេះ ចាំបាច់ត្រូវព្យាបាលដោយប្រើថ្នាំសម្លាប់ផ្សិត Benomy Carbendazin Thiabendazole ឬ Thiophonateemthy លាយជាមួយគ្នាការពារផ្សិត MancozebPropined ឬ Chloro Thaloni ហើយនិងថ្នាំសម្លាប់សត្វល្អិតដែលសមស្របសម្រាប់សម្លាប់សត្វល្អិតដែលបឺតយករុក្ខរសពីស្លឹក ស្លឹកដែលទើបជ្រុះដោយសារជំងឺនេះ ត្រូវប្រមូលយកចេញ ហើយដុតចោលដើម្បីបំបាត់ប្រភពនៃជំងឺពីថ្នាលបណ្តុះកូន។

**វិធីម្យ៉ាងទៀត:** បាញ់ថ្នាំ គូបវ៉ារីធ ឬ ប៊ិឌូមីន គឺធ្វើការបាញ់ពី៧ថ្ងៃម្តង ឬ ១០ថ្ងៃម្តង ។

ជំងឺ Leaf blight:

ជាប្រភេទជំងឺ មានលក្ខណៈស្រួចស្រាវលើដំណាំសាវម៉ាវ ជាពិសេសនៅតំបន់អាស៊ីអាគ្នេយ៍យើងនេះ។



**រោគសញ្ញា:** ច្រើនកើតឡើងនៅលើស្លឹក ផ្កា ដោយបង្កឱ្យរួញស្វិត ជាទូទៅជំងឺនេះគេតែងសង្កេតឃើញវាកើតឡើងនៅពេលមិនមានការស្រោចស្រពត្រឹម ត្រូវ ទឹកដកមានរយៈយូរ ការប្រើប្រាស់ជីហួសកម្រិត និងដីមានកម្រិតPHទាប។

**វិធានការការពារ:**

ធ្វើការសម្អាតក្នុងចម្ការ ស្រោចស្រពឱ្យបានត្រឹមត្រូវ ជៀសវាងការដាំដំណាំលើដីដក់ទឹក ឬដីអាស៊ីត ពិសេសការប្រើប្រាស់ជីឱ្យបានសមស្របតាមកម្រិតណែនាំរបស់អ្នកជំនាញ។

**ជំងឺខ្វះជីជាតិ** : កូនសាវម៉ាវ និងដើមធូរេន ដែលដាំនៅកន្លែងថ្មី ក្នុងរយៈពេល ២ ឆ្នាំដំបូង ឆាប់ទទួលរងជំងឺងាយជាងដើម សាវម៉ាវចាស់ៗ បើខ្វះមីក្រូ និងម៉ាក្រូជីជាតិ និង ករណីអតុល្យភាពនៃជីជាតិ ឥទ្ធិពលដ៏ចម្បងនៃការខ្វះជីជាតិ គឺការពន្យាពេលក្នុងការលូតលាស់ និងការអភិវឌ្ឍ ហើយរុក្ខជាតិមានសភាពតឿយូរ ។ រុក្ខជាតិដែលខ្វះជីជាតិមានទំនោរផ្លែច្រើន ចុងក្រោយមិនទៀងទាត់ ហើយផ្តល់ផលទាបដោយសារតែការជ្រុះក្តិប ដែលបណ្តាលមកពីការខ្វះជីជាតិបំរ៉ុងក្នុងដើម ។

✔ ការខ្លះជាតិអាសូត: រោគសញ្ញាបង្ហាញឱ្យឃើញ ស្លឹកឡើងពណ៌លឿងខ្ចីដោយមិនជ្រុះមកលើដី ហើយសរសៃស្លឹកក៏មានពណ៌លឿងដែរ ។

✔ ការខ្វះជាតិផូស្វ័រ: ស្លឹកមានទំហំតូចជាងស្លឹក ដែលមានជីជាតិគ្រប់គ្រាន់

✔ ការខ្វះជាតិប៉ូតាស្យូម: មានរោគសញ្ញាលេចឡើងលើស្លឹកចាស់ៗ មានពណ៌លឿងនៅចុងស្លឹក ហើយចេះតែបន្តតាមគែមស្លឹក បន្ទាប់មកក្លាយជាពណ៌ត្នោត ។

✔ ការខ្វះជាតិកាល់ស្យូម: ស្លឹកងាប់ចុងលើស្លឹកខ្ចីល្មម និងស្លឹកចាស់ ។

✔ ការខ្វះជាតិម៉ាញ៉េស្យូម: មានពណ៌លឿងលើស្លឹកចាស់ៗ ដែលចាប់ផ្តើមពីធាងស្លឹក ហើយបន្តរហូតដល់ជាយស្លឹក ប៉ុន្តែជាយស្លឹកផ្សេងៗទៀតនៅតែពណ៌បៃតង ចំណែកឯស្លឹកដែលទទួលរងជំងឺអាចជ្រុះ ។

✔ ការខ្វះជាតិស្ពាន់ធ័រ : រោគសញ្ញាដំបូងគឺកើតលើស្លឹកខ្ចី ពេលនៅតូចហើយប្រែពណ៌ជាបៃតង ប៉ុន្តែធាងស្លឹកនៅតែពណ៌បៃតងខ្ចី ។ ស្លឹកដែលទទួលរងជំងឺប៉ោងឡើងលើផ្ទៃស្លឹក ។

✔ ការខ្វះជាតិដែក: ស្លឹកខ្វះជាតិក្លរ៉ូភីល តែធាងស្លឹកនៅតែមានពណ៌បៃតង

✔ ការខ្វះជាតិម៉ង់កាណែស : ស្លឹកបាត់បង់ក្លរ៉ូភីល ហើយមានពណ៌លឿងធាងស្លឹកនៅតែមានពណ៌បៃតង ស្លឹកដែលទទួលរងជំងឺតែងតែជ្រុះ ។

✔ ការខ្វះជាតិទង់ដែង: ស្លឹកខ្ចីរួញខ្លី ហើយស្លឹកមានពណ៌ត្នោត ពន្លកស្លឹកក្រោយមកក៏ងាប់។

### វិធានការការពារ និង ព្យាបាល :

ជំងឺខ្វះជីជាតិ អាចជៀសវាងបាន ដោយការដាក់ជីឱ្យបានគ្រប់គ្រាន់ និងសមស្រប ។ តម្រូវការជីប្រែប្រួលទៅតាមប្រភេទនៃដី ។ ដើម្បីកំណត់តម្រូវការជី និងរយៈពេលនៃការដាក់ជីឱ្យបានត្រឹមត្រូវ ត្រូវមានការវិភាគស្លឹក និងវិភាគដី ។ ជាទូទៅ នៅដំណាក់កាលដំបូងនៃការលូតលាស់របស់រុក្ខជាតិ ត្រូវការបរិមាណអាសូត ផូស្វ័រ និង ម៉ាញ៉េស្យូមច្រើន ។ ក្នុងរយៈពេលចេញផ្កា និង ផ្លែ រុក្ខជាតិត្រូវ

ការជីសរីរាង្គ ជីផូស្វ័រ និងប៉ូតាស្យូម។ សម្រាប់ការស្រូបយកសមស្របនៃជីជាតិម៉ាក្រូ និងមីក្រូ ដែលនៅជុំវិញដើម គួរតែមានជាតិកំបោរ ។

ការខ្វះជីជាតិ អាចប្រើប្រាស់ជីគីមីបន្ថែមដើម្បីជំនួយដល់ស្លឹក ដោយបាញ់ទៅលើស្លឹកនូវល្បាយសូលុយស្យុជី។

✓ **ជំងឺខ្វះទឹក :** ចំពោះរុក្ខជាតិពេញវ័យ រោគសញ្ញានៃការខ្វះទឹកដែលបានជួបប្រទះក្នុងពេលរាំងស្ងួត គឺសម្គាល់ដោយស្លឹកប្រែ ទៅជាពណ៌លឿង ហើយជ្រុះមុនពេលកំណត់ ដោយបន្សល់ទុកឱ្យដើមមានតែមែកសុទ្ធ ។ រុក្ខជាតិដែលមានតែមែក (គ្មានស្លឹក) ងាយកើតជំងឺ ដូចជាជំងឺផ្សិត Lasiodiphodia theobromate និង Colletotrichum gloeosporides ។ ជំងឺទាំងនេះបណ្តាលឱ្យដំណាំសាវម៉ាវងាប់ជាបន្តទៀត នូវមែកតូច ធំ ។ ភាពស្រពោនដោយការរាំងស្ងួតកើតឡើងនៅពេលដែលមានសំណើមទាប កម្តៅថ្ងៃឡើងខ្ពស់ និងមានខ្យល់ខ្លាំង ។ ប៉ុន្តែរុក្ខជាតិភាគច្រើនលូតលាស់ឡើងវិញ នៅពេលដែលមានអាកាសធាតុត្រជាក់ ហើយមានការដាក់ជីគ្រប់គ្រាន់ក្នុងករណីធ្ងន់ធ្ងរ ធ្វើឱ្យភាពរឹងមាំរបស់ដើមថយចុះ និងធ្វើឱ្យឆាប់រងការវាតត្បាតពីមេរោគមួយចំនួនដូចជា Phytophorapalmivara នៅពេលរដូវក្តៅសើមចូលមកដល់ ។

**វិធានការការពារ និង ព្យាបាល:** ដើម្បីជៀសវាងការស្វិតស្រពោនដោយការខ្វះទឹក ដើមសាវម៉ាវចាំបាច់ត្រូវផ្តល់ទឹកឱ្យបានគ្រប់គ្រាន់ តាំងពីពេលដាំរហូតដល់ពេលចេញផ្កា ។ ប្រព័ន្ធស្រោចស្រពគឺជាដំណោះស្រាយដ៏ល្អ ក្នុងការស្រោចស្រពដំណាំសាវម៉ាវ ។ ក្នុងរដូវប្រាំង ដើមឈើគួរតែត្រូវបានគេស្រោចស្រពយ៉ាងហោចណាស់ក៏មួយដងក្នុងមួយថ្ងៃ ។ លើសពីនេះ គួរឱ្យមានម្លប់ ដែលបានពីការដាក់ធាងត្នោតលើដើមសាវម៉ាវតូចៗ រួមជាមួយការដាក់កម្ទេចសម្រាមដូចជាស្មៅស្ងួតៗជុំវិញដើមសាវម៉ាវ ។ ការធ្វើដូច្នេះ អាចជួយការពារភាពស្ងួត និងកម្តៅចាំង។

**ជំងឺបន្ទាប់បន្សំក្រោយប្រមូលផល:** ជំងឺផ្សិតជាច្រើនដែលបំផ្លាញដំណាំសាវម៉ាវក្រោយពេលប្រមូលផលរួចដូចជា : កើតនៅពេលដឹកជញ្ជូន ឬការថែរក្សាទុក ។ ជំងឺ

ផ្សិតទាំងនោះរួមមាន Colletory Chum glocosportoides ដែលជាភ្នាក់ងារចម្លងជំងឺ Anthrachose។ ជំងឺនេះជ្រាបចូលទៅក្នុងសាច់ផ្លែ បណ្តាលឱ្យផ្លែរលួយស្អុយ ជួរ សម្បកផ្លែប្រែជាពណ៌ត្នោត ឬពណ៌ត្នោតក្រម៉ៅ ។ នៅពេលគេប្រមូលផលផ្លែនៅខ្ចីពេក ការទុកដាក់ ដោយខ្វះខ្យល់ចេញចូល និងទុកដាក់នៅកន្លែងមានសីតុណ្ហភាពខ្ពស់ ធ្វើឱ្យផ្លែសាវម៉ាវឆាប់ទទួលរងពីការរាតត្បាត ពីសំណាក់ជំងឺទាំងនេះណាស់ ដូចនេះ ដើម្បីការពារពីជំងឺនេះ គេត្រូវរក្សាផ្លែទុកឱ្យមានខ្យល់ចេញចូលគ្រប់គ្រាន់ នៅសីតុណ្ហភាពទាប និងការប្រមូលផលផ្លែនៅពេលចាស់ល្អ ។

### ៨.៣. ពពួករុក្ខជាតិចង្រៃ:

រុក្ខជាតិចង្រៃមាន :

- ✓ ស្មៅចិញ្ចៀន
- ✓ ស្មៅសក់សេះ
- ✓ កន្ទ្រាំងបាយស
- ✓ ស្មៅបារាំង
- ✓ ស្មៅជើងក្រាស់នឹងរុក្ខជាតិផ្សេងៗទៀតដែលដុះនៅចន្លោះជួរ និង ចន្លោះគុម្ពដើមសាម៉ាវ ដើម្បីស្រូបយកទឹក និងសារធាតុចិញ្ចឹម ពីក្នុងដីដែលធ្វើឱ្យរំខានដល់ការដុះលូតលាស់របស់ដើមសាវម៉ាវ ។

វិធានការការពារ និង ព្យាបាល :

- ✓ សម្អាតឱ្យបានស្អាត ដោយប្រើម៉ាស៊ីន និងកម្លាំងពលកម្ម
- ✓ ប្រើថ្នាំ Roundup 480 SC
- ✓ ប្រើថ្នាំស្មៅ

## ៩. ការប្រមូលផល ៖

ដំណាំសាវម៉ាវចាប់ផ្តើមផ្តល់ផ្លែផ្កាពីអាយុ ៤-៦ ឆ្នាំ បន្ទាប់ពីដាំ។ ប៉ុន្តែចំពោះដើមផ្សាំ ឬបំបៅវិញ អាចផ្តល់ផ្លែផ្កានៅក្នុងរយៈពី ២-៤ ឆ្នាំប៉ុណ្ណោះ។ ការប្រមូលផល គេច្រើនធ្វើឡើងនៅខែសីហា រហូតដល់ខែកញ្ញា ។ ប្រសិនបើគិតចាប់



ពីចេញផ្កាមក មានរយៈពេលពី ៩០-១១០ ថ្ងៃ ឬអាចច្រើនជាងនេះ អាស្រ័យទៅតាមប្រភេទពូជ ។ ផ្លែសាវម៉ាវនៅពេលខ្ចី(មិនទាន់ចាស់) មានសំបកពណ៌ខៀវ ។ ប៉ុន្តែនៅពេលទុំ សំបករបស់វាប្រែទៅជាពណ៌លឿង ឬក្រហម អាស្រ័យទៅតាមពូជ។ ទិន្នផលមធ្យមក្នុង១ដើមបានចំនួន៦០-៧០ គីឡូក្រាមក្នុង១ដើម និងអាចរក្សាទុកផ្លែមិនឱ្យបាត់រសជាតិផ្អែមឆ្ងាញ់ក្នុងកម្រិតសីតុណ្ហភាពពី១៣-១៦ C° ។





## ៩.១ វិធីសាស្ត្រប្រមូលផល :

ផ្លែសាវម៉ាវទុំ គេអាចសម្គាល់លើពណ៌របស់ផ្លែ ក្រៅពីនេះគេអាចសង្កេតមើលទៅលើទងផ្លែ បើទុំ ទងមានលក្ខណៈស្ងួតហើយមានពណ៌ប្រផេះ ចុងព្រុយរបស់ផ្លែក៏មានលក្ខណៈដូចទងផ្លែដែរ ។ មុននិងប្រមូលផល គេអាចបេះសាវម៉ាវមកបរិភោគមើលសិនជាការប្រសើរ។

តាមធម្មតា ផ្លែសាវម៉ាវទុំមិនស្រុះគ្នាទេ ក្នុងចង្កោមនីមួយៗ ដោយមានខ្លះខ្ចី ខ្លះចាស់ នៅលាយឡំគ្នា ដូច្នេះការប្រមូលផលត្រូវកាត់យកផ្លែណាដែលទុំ ឬចាស់តែប៉ុណ្ណោះ។ វិធីសាស្ត្រ ក្នុងការប្រមូលផលផ្លែសាវម៉ាវមានច្រើនវិធី៖

- ការប្រើកន្ត្រៃកាត់សណ្តង់ទង
- ការប្រើកាំបិតកាត់សណ្តង់ទង
- ការប្រើដៃកាច់សណ្តង់ទង វិធីនេះគេមិនប្រើទេ ព្រោះវាអាចបណ្តាលឱ្យបាក់មែកច្រើន ហើយធ្វើឱ្យដើមសាវម៉ាវឆាប់អន់ ។

ក្នុងពេលកាត់ប្រមូលផលសាវម៉ាវ ត្រូវប្រុងប្រយ័ត្ន កុំឱ្យរោមផ្លែសាវម៉ាវជាំ ព្រោះមិនអាចទុកបានយូរ ហើយនិងមានពណ៌សម្បុរមិនទាក់ទាញ ។ ក្នុងមួយរដូវកាលរបស់ដំណាំសាវម៉ាវ គេពុំអាចប្រមូលផលតែម្តងអស់ទេ ជាទូទៅ គេធ្វើការប្រមូលពី២-៣លើក ទើបអស់ ហើយការប្រមូលមួយលើកៗមានចន្លោះឃ្លាតពី៧-១០ថ្ងៃ៕

AIDOC
Code:
Date:
Donated by:

## ឯកសារយោង៖


1. លោក ផាត់ មុន្នី ដំណាំឈើហូបផ្លែ, ១៩៩៥
2. លោក កង អួន ក្សេត្រគីមី, ១៩៩៧
3. លោក ម៉ែន សុវណ្ណា អគ្គបទស្រាវជ្រាវផ្នែកកសិកម្ម ស្តីពីដំណាំសាវម៉ាវ
4. ឯកសារបច្ចេកទេស ដំណាំឈើហូបផ្លែ,១៩៩៩ ( ស្ថានីយ៍កសិកម្ម បែកចាន ខេត្តបាត់ដំបង
5. Mr. E.W.M Verheij and RE. Coronel Bogor Indonesia, 1992 (PlanResources of South East Asia Edible fruits and nuts)
6. Mr. Roberto E cononel P.H.D First Printing, 1983 (Promisiong Fruits of the Philippines)
7. Mr. TOHMAN YAACOB SURANNANT. SUBHA DRABANDHD, 1995 (The Production of Economic Fruits in South East Asia).
8. Prosea; Plant Resources of south East Asia
9. Codex Standard for fresh friut and Vigetable, 2005 (Codex Standard for Rambutant, 246-2005)
10. Improved production technology of Rambutant, P.C Tripathi, V.Sankar and R. Senthi Kumar. 2000



**អាសយដ្ឋាន** : ផ្ទះលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចម្ការមន រាជធានីភ្នំពេញ

**ទូរស័ព្ទលេខ** : (០២៣) ២១៥ ៨១៩/០១២ ៨៣ ៧៩ ៤៥

**ទូរសារលេខ** : (៨៥៥)២៣ ២១០ ៩៤៨

**Facebook** : នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម - **Department of Agricultural Extension**

**គេហទំព័រ** : **http://www.maff.gov.kh**